# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិត សាស្ត្រាចារ្យ និស្សិត កម្មករ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជា មហាជនទូទៅ បានតាមដានស្តាប់យ៉ាងយកចិត្តទុកដាក់នូវសេចក្តីថ្លែងការណ៍ប្រកបដោយអត្ថន័យដ៏ជ្រាលជ្រៅជាប្រវត្តិសាស្ត្រកាលពីរសៀលថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីផ្តល់ការបំភ្លឺជូនដល់ជនរួមជាតិកម្ពុជាស្តីពីផែនទីព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាពិសេសព្រឹត្តិការណ៍ចុងក្រោយទាក់ទងនឹងការផ្ទៀងផ្ទាត់ផែនទី ដែលផ្តល់ដោយអង្គការសហប្រជាជាតិ និងដោយសាធារណរដ្ឋបារាំង ដែលបានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីសច្ចភាពនិងភាពត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម ដោយធានាការពារឱ្យបាននូវបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងមិនឱ្យមានការបាត់បង់ជាដាច់ខាត សូម្បីតែមួយម៉ែត្រក្រឡាក៏ដោយ។ ជាមួយគ្នានេះដែរ ក៏បានបង្ហាញឱ្យឃើញច្បាស់ពីល្បិចកលនយោបាយដ៏ពិសពុលរបស់មជ្ឈដ្ឋានអគតិមួយចំនួនដែលនៅតែបន្តបិទភ្នែក បិទត្រចៀកនិងធ្វើជាមិនយល់អំពីកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធានាការពារបូរណភាពទឹកដីមិនឱ្យមានការបាត់បង់ និងបានបន្តលើកយកប្រធានបទនេះមកធ្វើការឃោសនា ញុះញង់ បំផុសបំផុលបំផ្លើសបំភ្លៃការពិត បំភ័ន្តមតិសាធារណៈជាតិនិងអន្តរជាតិហើយអូសទាញបោកបញ្ឆោតទឹកចិត្តស្នេហាជាតិពិតប្រាកដរបស់បងប្អូនជនរួមជាតិខ្មែរមកលើរាជរដ្ឋាភិបាល ក្នុងគោលបំណងកេងចំណេញផលប្រយោជន៍ខាងនយោបាយ ដោយចោទប្រកាន់ថាផែនទីព្រំដែនផ្លូវការនិងស្របច្បាប់ ដែលរាជរដ្ឋាភិបាលកំពុងប្រើប្រាស់ស្របច្បាប់នោះជាផែនទីក្លែងក្លាយ មិនត្រឹមត្រូវ ឬជាផែនទីចោរទៀតផង ដែលកត្តានេះជាការប្រមាថឥតកោតក្រែងទៅលើស្ថាប័នកំពូលរបស់ជាតិរួមទាំងព្រះមហាក្សត្រផង។

ក្នុងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ និយោជិត សាស្ត្រាចារ្យ និស្សិត កម្មករ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់សូមប្រកាសគាំទ្រយ៉ាងឱឡារិកចំពោះរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតនិងម៉ឺងម៉ាត់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែបូជាកម្លាំងកាយ ចិត្ត និងប្រកាន់ខ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុង្គឧត្តមក្នុងការការពារបូរណភាពទឹកដីនិងអធិបតេយ្យជាតិ ជាពិសេសក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតចំពោះជោគវាសនាប្រទេសជាតិនិងមាតុភូមិទាំងមូល។

យើងខ្ញុំទាំងអស់គ្នា សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះទង្វើរបស់ជនអគតិទាំងនោះដែលតែងតែធ្វើការប្រឌិតនិងចោទប្រកាន់ មួលបង្កាច់ទាំងងឹតងងល់នាពេលកន្លងមក ដើម្បីបម្រើនយោបាយប្រជាភិថុតរបស់បក្សពួកខ្លួនមកលើកិច្ចខិតខំប្រឹងប្រែងយ៉ាងស្មោះស និងដើម្បីឧត្តមប្រយោជន៍ជាតិរបស់រាជរដ្ឋាភិបាលក្នុងការងារព្រំដែននេះ និងសូមអំពាវនាវម្តងហើយម្តងទៀតដល់អាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការតាមផ្លូវច្បាប់ឱ្យមានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋក្នុងគោលបំណងថែរក្សាសន្តិភាព ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈនៃមាតុភូមិកម្ពុជា។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320